# ការសំភាសន៍របស់ ម៉ាក់យាយ កែវ គី

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍មាន កែវ គី

<u>ការសង្ខេបប្រវត្តិរបស់ ម៉ាក់យាយ កែវ គី</u>

ម៉ាក់យាយ កែវ គី មានអាយុ69ឆ្នាំ នៅឆ្នាំ2018 ម៉ាក់យាយ កែវ គី មានភេទ ស្រី ម៉ាក់យាយ កែវ គី មានទីលំនៅបច្ចុប្បន្ននៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ជាដំបូងខ្ញុំអរគុណច្រើនម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថាBYUហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកកាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយ នឹងដូនតាចឹងហាសម៉ាក់យាយ ហើយនៅពេលដែរពួកយើងសំភាសន៍ហើយយើងនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu ចឹងហាសម៉ាក់យាយ ចឹងសំរាប់ម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលដែរទេម៉ាក់យាយ?

ខៈ ដាក់ៗទៅចៅ។

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ម៉ាក់យាយខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ម៉ាក់គីនៅថ្ងៃទី6 ខែ2 ឆ្នាំ2018 ចឹងនៅនឹងភូមិ5ណាម៉ាក់យាយ?

ខៈ នឹងហើយភូមិ5។

កៈ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹងខ្ញុំសំសួរម៉ាក់យាយមួយបានទេ ថាម៉ាក់យាយឈ្មោះពេញរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ខ្ញុំឈ្មោះកែវ គី។

កៈ ឈ្មោះ កែវ គី ចុះមានឈ្មោះហៅក្រៅទេម៉ាក់យាយ?

ខៈ ឈ្មោះក្រៅក៏ឈ្មោះចឹងដែរ។

កៈ ចុះតាំងពីក្មេងមក តើម៉ាក់យាយមានដៃរប្តូរឈ្មោះអីទេ?

ខៈ អត់ទេ អត់ដៃរប្តូរទេ។

កៈ ចឹងកាលពីនៅក្មេងអត់មាននរណាហៅឈ្មោះម៉ាក់យាយអីផ្សេងទេណាម៉ាក់យាយ?

ខៈ អត់មានទេ។

កៈ ចុះម៉ាក់យាយសព្វថ្ងៃអាយុប៉ុន្មានដៃរម៉ាក់យាយ?

ខៈ ខ្ញុំអាយុ69ឆ្នាំ។

កៈ ចុះម៉ាក់យាយមានដឹងថាម៉ាក់យាយកើតនៅថ្ងៃខែឆ្នាំណាដៃរទេម៉ាក់យាយ?

ខៈ អត់ដឹងទេខ្ញុំភ្លេចបាត់ហើយនឹងហាស។

កៈ ចឹងឆ្នាំក៏អត់ដឹងដៃរហោសម៉ាក់យាយ?

ខៈ អត់ដឹងទេ ឆ្នាំដឹងតែឆ្នាំខាល។

កៈ ឆ្នាំខាល ចឹងម៉ាក់យាយកើតនៅឆ្នាំ1958ហាស។

ខៈ ចាំ!នឹងហើយ។

កៈ ចុះម៉ាក់យាយកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីដៃរម៉ាក់យាយ?

ខៈ នៅភូមិកំពង់ស្រូវ ស្រុកកំពង់រូល ខេត្តស្វាយរៀង។

កៈ ចុះម៉ាក់យាយសព្វថ្ងៃម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មានដៃរម៉ាក់យាយ?

ខៈ បងប្អូនមានចំនួន3នាក់ ប៉ុន្តែស្លាប់បាត់អស់ហើយនឹងហាស។

កៈ នៅសល់តែម៉ាក់យាយមួយទេ?

ខៈ ខ្ញុំនៅតែម្នាក់ឯងនឹង។

កៈ ចុះម៉ាក់យាយជាកូនទីប៉ុន្មានដៃរម៉ាក់យាយ?

ខៈ ខ្ញុំជាកូនច្បង។

កៈ ចុះមានស្រីប៉ុន្មាន ហើយនឹងប្រុសប៉ុន្មានដៃរម៉ាក់យាយ?

ខៈ ខ្ញុំមានស្រីតែម្នាក់ឯងនឹងហាស នឹងប្អូនប្រុស2នាក់បានស្លាប់បាត់អស់ហើយ។

កៈ ប៉ុន្តែប្អូនប្រុសដៃរស្លាប់នឹងគាត់មានឈ្មោះអីគេដៃរម៉ាក់យាយ?

ខៈ វាឈ្មោះ អាកណ្តាលឈ្មោះអាទិត្យ អាប្អូនឈ្មោះអាចន។

កៈ អូ៎!ម៉ាក់យាយមានដឹងថាហេតុអីបានពួកគាត់ស្លាប់ទេ?

ខៈ ស្លាប់នៅជំនាន់លន់ណុល។

កៈ គាត់ធ្វើអីគេដែរនៅជំនាន់លន់ណុលដែរម៉ាក់យាយ?

ខៈ គេធ្វើជាទាហ៊ានលន់ណុល។

កៈ ដូចជាហេតុអីបានជាគាត់ស្លាប់ចឹងហាស គាត់ស្លាប់ដោយសារតែជំងឺរឺមួយស្លាប់ដោយសារអីចឹងហាសម៉ាក់យាយ?

ខៈ គេស្លាប់ដោយសារតែគេបាញ់ធ្លាក់ពីលើដើមឈើនឹងអាកណ្តាល។

កៈ អូ៎!បាទម៉ាក់យាយ ចុះប្អូនវិញ?

ខៈ ចំណែកអាពៅវិញស្លាប់ដោយសារតែជំងឺ។

កៈ ប៉ុន្តែនៅជំនាន់លន់ណុលទាំងអស់គ្នា?

ខៈ អត់ទេ អាពៅស្លាប់នៅពេលជំនាន់ហ៊ុនសែននឹងតា។

កៈ អូ៎!ចឹងមានន័យថាគាត់ទើបតែស្លាប់ទេហោសម៉ាក់យាយ?

ខៈ នឹងហើយទើបតែស្លាប់នឹងហាស។

កៈ ចុះម៉ាក់យាយមានចងចាំសាច់រឿងអីខ្លះកាលពីម៉ាក់យាយនៅតូចហាសជាមួយពួកគាត់ដែរទេម៉ាក់យាយ?

ខៈ សាច់រឿងអីគេ?

កៈ ចង់និយាយថាធ្លាប់ធ្វើអីគេខ្លះជាមួយបងប្អូនរបស់ម៉ាក់យាយ?

ខៈ គ្មានរឿងអីទេ អត់ដែរមានរឿងអីទេ។

កៈ លក្ខណះថាដូចថាលេងឡឹកបាយឡ លេងបិទពួន រឺក៏ធ្លាប់ដើរលេងជាមួយគ្នារឺទៅស្រែអីជាមួយគ្នាចឹងហាស?

ខៈ អត់មានទេ។

កៈ អូ៎!អត់មានធ្លាប់ទេ?

ខៈ នឹងហើយទៅរៀន ពេលដែរឈប់រៀនទៅក៏រកស៊ីទៅ។

កៈ ប៉ុន្តែកាលពីនៅក្មេងៗអីហាស?

ខៈ នឹងហើយ។

កៈ អូ៎!បាទម៉ាក់យាយ សំរាប់ប្តីរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ តារបស់ខ្ញុំគាត់មានឈ្មោះវ័ត្ន ផានី។

កៈ ចុះម៉ាក់យាយរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាម៉ាក់យាយមានចងចាំទេ?

ខៈ អត់ចាំផងនៅពេលដែរបែកជំនាន់វៀតណាមនឹង។

កៈ បែកវៀតណាម ចុះនពេលដែរម៉ាក់រៀបការហើយ
ម៉ាក់យាយមានកូនតែម្តងរឺមួយយ៉ាងម៉េចដែរម៉ាក់យាយ?

ខៈ ការហើយខ្ញុំមានកូន។

កៈ ចុះកូនរបស់ម៉ាក់យាយនឹង កូនបងអាយុប៉ុន្មានដែរហើយម៉ាក់យាយ?

ខៈ បងស្រីមីមួយមុននឹងវាអាយុ42ឆ្នាំហើយនឹងហាស។

កៈ ចឹងមានន័យថាម៉ាក់យាយការអស់រយៈពេល42ឆ្នាំហើយណាម៉ាក់យាយ?
ខៈ នឹងហើយប្រហែលជាប៉ុណ្ណឹង។

កៈ ចឹងម៉ាក់យាយការនៅឆ្នាំ1976។

ខៈ នឹងហើយនៅជំនាន់ពលពត។

កៈ ចឹងនៅពេលដែរម៉ាក់យាយការនឹងដូចជាម៉ាក់យាយរៀបចំដោយខ្លួនឯង
រឺមួយក៏ម្តាយឪពុករបស់ម៉ាក់យាយជាអ្នករៀបចំអោយដែរ?

ខៈ ខ្ញុំមានប្តី2នាក់ ប្តីមុននឹងឪពុកម្តាយជាអ្នករៀបចំអោយ
ប៉ុន្តែដល់ពេលដែរប្តីក្រោយនឹងខ្ញុំអ្នករៀបចំខ្លួនឯង។

កៈ ចុះសំរាប់ប្តីមុននឹងពេលដែរម៉ាក់យាយការនឹង គាត់អោយជាជំនូនទេម៉ាក់យាយ?

ខៈ ថីមិនអោយ។

កៈ ចុះពេលណុងគេអោយអីគេដែរម៉ាក់យាយ?

ខៈ អោយផ្លែឈើសព្វគ្រប់នឹងហាស។

កៈ ប៉ុន្តែដូចជាអត់មានជាមាសអីទេ នៅពេលណុងណាម៉ាក់យាយ?

ខ៖  អត់មានមាសទេ មានតែលុយកាក់។

ក៖  ចុះហេតុអីបានជាម៉ាក់យាយពេញចិត្តជាមួយតា ហេតុអីបានម៉ាក់យាយស្រលាញ់តា ហើយតាស្រលាញ់ម៉ាក់យាយចឹងហាស ហើយស្រលាញ់នឹងអស់រយះពេលប៉ុន្មានឆ្នាំដែរបានតាចូលស្ដីដណ្ដឹងម៉ាក់យាយចឹងហាស ?

ខ៖  ស្រលាញ់គ្នាបានមួយឆ្នាំ។

ក៖  ហើយបានចូលស្ដីដណ្ដឹងម៉ាក់យាយ?

ខ៖  នឹងហើយពេលដែរបានកូនមួយក៏បែកគ្នា។

ក៖  ចុះម្ដាយរបស់ម៉ាក់យាយគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  ម្ដាយរបស់ខ្ញុំកាត់មានឈ្មោះរស់ សូ។

ក៖  គាត់មានឈ្មោះរស់ សូ ចុះគាត់កើតនៅឆ្នាំណាម៉ាក់យាយមានដឹងទេ?

ខ៖  អត់ដឹងទេ។

ក៖  ចុះគាត់អាយុប៉ុន្មានម៉ាក់យាយអត់ដឹងទេ?
ខ៖  គាត់អាយុប៉ុន្មានដែរអត់ដឹងទេ ដឹងតែគាត់អាយុជំណើរសម្ដេចតា។

ក៖  អូ៎!ជំណើរសម្ដេចតា?
ខ៖  នឹងហើយដឹងតែគាត់ឆ្នាំមមី

ក៖  ប៉ុន្ដែគាត់នៅឆ្នាំណាម៉ាក់យាយអត់ចាំទេណម៉ាក់យាយ?

ខ៖  ខ្ញុំអត់ចាំទេ។

ក៖  សម្ដេចតាឥឡូវនឹងចង់មួយរយឆ្នាំហើយ?

ខ៖  អត់ដឹងទេ។

ក៖  ចុះឪពុករបស់ម៉ាក់យាយគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  គាត់ឈ្មោះចាប ហៃល។

ក៖  គាត់ឈ្មោះចាប ហៃល ចុះគាត់អាយុប៉ុន្មានក៏ម៉ាក់យាយអត់ដឹងដែរណ?

ខ៖  ខ្ញុំអត់ដឹងទេ ដឹងតែគាត់ឆ្នាំកោនឹងហាស គាត់អាយុប្អូនម្ដាយរបស់ខ្ញុំ5ឆ្នាំ។

កៈ អ្ហូ!គាត់ប្អូន5ឆ្នាំហោសម៉ាក់យាយ
ចុះគាត់ទាំងពីរនាក់គាត់កើតនៅណាម៉ាក់យាយមានដឹងទេ?

ខៈ គាត់កើតនៅស្រុកជាមួយគ្នានឹងហាស។

កៈ អ្ហូ!នៅស្រុកជាមួយគ្នាហោសម៉ាក់យាយ?
ខៈ នឹងហើយនៅស្រុកណុងឯង នៅស្រុកកំពង់រូល ខេត្តស្វាយរៀង។

កៈ បាទម៉ាក់យាយ ចុះឪពុករបស់ម៉ាក់យាយធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ ឪពុករបស់ខ្ញុំពីដើមគាត់ធ្វើអាចារ្យ។

កៈ អ្ហូ!គាត់ធ្វើអាចារ្យហោសបង?

ខៈ ចាំ!នឹងហើយ។

កៈ ចឹងមានន័យថាគាត់ធ្វើអាចារ្យសំរាប់ចិញ្ចឹមគ្រួសារមួយយ៉ាងម៉េចដែរម៉ាក់យាយ?

ខៈ នឹងហើយគាត់ធ្វើអាចារ្យធ្វើស្រែ ។

កៈ អ្ហូ!គាត់ធ្វើស្រែដែរហោសម៉ាក់យាយ?

ខៈ គាត់ធ្វើស្រែ។

កៈ ចុះម្តាយរបស់ម៉ាក់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមចីវិតដែរម៉ាក់យាយ?

ខៈ ម្តាយរបស់ខ្ញុំកាត់ចិញ្ចឹមជ្រូកធ្វើអីដែរនឹងហាស។

កៈ បាទម៉ាក់យាយ
ចុះឪពុករបស់ម៉ាក់យាយគាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរម៉ាក់យាយ?

ខៈ គាត់ស្លូតដែរនឹងហាស។

កៈ ចុះម្តាយរបស់ម៉ាក់យាយវិញគាត់ស្លូត រឺមួយក៏កាចដែរម៉ាក់យាយ?

ខៈ ម្តាយរបស់ខ្ញុំក៏ចឹងដែរនឹងហាស។

កៈ គាត់ស្លូតដែរហោសម៉ាក់យាយ
ចុះម៉ាក់យាយមានចងចាំអីគេខ្លះកាលពីម៉ាក់យាយនៅជាមួយឪពុកម្តាយទេ?

ខៈ អត់ទេ។

កៈ អត់មានថាធ្លាប់ធ្វើអីជាមួយពួកគាត់ទេហោសម៉ាក់យាយ?

ខ៖ អត់ដែរមានធ្វើអីផងនឹង។

ក៖ ចុះម៉ាក់យាយធ្លាប់គិតថាធ្លាប់ទៅស្រែ
រឺមួយទៅដកស្ទូងអីជាមួយពួកគាត់ដែរទេម៉ាក់យាយ?

ខ៖ គ្មានទេ ទៅដកស្ទូងនឹង មានតែទៅធម្មតានឹងហាស។

ក៖ អូ្!ចឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយធ្វើស្រែ ធ្វើចំការនឹងហាស។

ក៖ បាទម៉ាក់យាយ
ចុះឪពុកម្តាយរបស់ម៉ាក់យាយធ្លាប់ប្រាប់ពីប្រវត្តិកាលពីពួកគាត់នៅក្មេងៗទៅម៉ាក់យាយទេ
?

ខ៖ គាត់ប្រាប់ដែរនឹងហាសដូចថាក្មេងៗសារក្រោយចឹងអត់ដឹងហាស
គាត់ថាបើចង់ធ្វើបុណ្យធ្វើទានអីនឹងកុំអោយធ្វើនៅខែចូលឆ្នាំ
អោយធ្វើខែភ្ជុំពីព្រោះខែភ្ជុំនឹងជាខែដែរវាអត់ហាស។

ក៖ បាទត្រូវហើយម៉ាក់យាយ។

ខ៖ ថាខែអត់នឹងធ្វើបុណ្យទៅវាបានបុណ្យណាស់ នឹងហើយតែធ្វើខែមានខែចូលឆ្នាំនឹង
គេមានគ្រប់គ្នាគេមិនសូវនឹកដើមទេ។

ក៖ អូ្!ចឹងហោសម៉ាក់យាយ។

ខ៖ គេមិនសូវមានប្រវត្តិក្រដល់ពេលចឹងវាមិនសូវបានបុណ្យទេនឹងហាស។

ក៖ អូ្!បាទម៉ាក់យាយ។

ខ៖ កាត់ថាចឹង ហើយខែក្រចឹងបានបុណ្យណាស់ គាត់និយាយប្រាប់ថាតែចឹង។

ក៖ បាទម៉ាក់យាយ ចុះមានអីទៀតទេម៉ាក់យាយ?

ខ៖ អត់មានអីទេថា កូនចៅទៅណាមកណាអីចេះគោរពចាស់ទុំនឹងហាស
នឹងកុំអោយឈ្លើយអីសោះគាត់ប្រដៅថាចឹងហាសណាស់។

ក៖ បាទត្រូវហើយម៉ាក់យាយ។

ខ៖ មិនថារៀនដេក រៀនដើរក៏ដោយ រៀនស៊ី រៀនអង្គុយសព្វគ្រប់ចឹងទៅគាត់អោយរៀនចេះអោយអស់នឹងហាស គាត់ថាកូនៗនឹងអោយតែចេះ3-4មុខនឹងគឺចេះហើយនឹងហាស។

ក៖ អូ៎!បាទល្អណាស់ម៉ាក់យាយ។

ខ៖ គាត់ថាចឹងហាស រៀនហូបអោយចេះហូបមើលគេមើលឯងចឹងទៅណាស់ រៀនដើរ រៀននិយាយ រៀនស្ដី រៀនអោយចេះប៉ុន្មានមុខនឹងរៀនចេះហើយនឹងហាស។

ក៖ ចុះម៉ាក់យាយមានចងចាំឈ្មោះយាយតាខាងម្ដាយទេ ថាពួកគាត់មានឈ្មោះអីគេដែរចឹងហាសម៉ាក់យាយ?

ខ៖ យាយតាខាងម៉ែរបស់ខ្ញុំមានឈ្មោះ តារស់ យាយដួប។

ក៖ ចុះគាត់កើតនៅឆ្នាំណាម៉ាក់យាយមានដឹងទេ?

ខ៖ អត់ដឹងទេ។

ក៖ ចុះគាត់អាយុប៉ុន្មានក៏ម៉ាក់យាយអត់ដឹងដែរណាម៉ាក់យាយ?

ខ៖ អត់ដឹងទេ ចុះកើតមកអត់ទាន់ផង គាត់ស្លាប់អស់ហើយនឹងហាស។

ក៖ ចុះយាយតាខាងឪពុកវិញម៉ាក់យាយមានស្គាល់ឈ្មោះកាត់ដែរទេ?

ខ៖ យាយតាខាងឪពុកនឹងក៏ចាំដែរ។

ក៖ គាត់ឈ្មោះងីគេដែរម៉ាក់យាយ?

ខ៖ យាយឈ្មោះយាយនួន តាឈ្មោះតា ដុក។

ក៖ ចុះគាត់កើតនៅឆ្នាំណាម៉ាក់យាយមានដឹងទេ?

ខ៖ អត់ដឹងទេ។

ក៖ ចុះគាត់អាយុប៉ុន្មានម៉ាក់យាយអត់ដឹងដែរ?

ខ៖ អត់ដឹងទេ ខ្ញុំកើតមកមិនទាន់ដែរនឹងហាស។

ក៖ ចុះម្ដាយឪពុករបស់ម៉ាក់យាយធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេង ថាគាត់ធ្លាប់ធ្វើអីគេដែរចឹងហាសម៉ាក់យាយ?

ខ៖ នឹងហើយគាត់លំបាកនឹងដែរនឹងហាស។

កៈ បាទម៉ាក់យាយ។

ខៈ មានកូនចៅ តែក៏អត់មានកូនច្រើនទេ មានតែ3នាក់នឹង ហើយបានមាន5ឆ្នាំបានកើតបានខ្ញុំមួយនឹងហាស។

កៈ អូ៎!5ឆ្នាំបានមានមួយហើយម៉ាក់យាយ?

ខៈ ហើយដល់5ឆ្នាំទៀតបានបានមួយទៀតនឹង ចឹងមានន័យថា15ឆ្នាំមានតែ3នាក់នឹងហាស។

កៈ ចុះម៉ាក់យាយបានមកនៅទីក្រុងភ្នំពេញនឹងយូរនៅម៉ាក់យាយ?

ខៈ ខ្ញុំមករស់នៅតាំងពីឆ្នាំ1979មក។

កៈ ឆ្នាំ1979 ចឹងអស់ប្រហែលជា39ឆ្នាំម៉ាក់យាយ?

ខៈ នឹងហើយតាំងពីឆ្នាំ1979នឹង។

កៈ អូ៎!ចុះមានអីទៀតទេ?

ខៈ តាំងពីដាច់វៀតណាមហើយហ៊ុនសែនកាន់កាប់នឹង។

កៈ ចឹងនៅនឹងរហូត?

ខៈ មកនៅនឹងរហូត។

កៈ ចឹងហោសម៉ាក់យាយ?

ខៈ ខ្ញុំទៅតែទៅលេងទេ។

កៈ ចុះម៉ាក់យាយគិតថា ម៉ាក់យាយនៅណុងរហូតតែម្តង រឺមួយក៏ម៉ាក់យាយមានការផ្លាស់ប្តូរទៅលំនៅកន្លែងផ្សេង?

ខៈ អត់ទេពីមុននៅលើថ្នល់នឹង ដលពេលដែរគេកដីធ្វើម៉ាស៊ីនទៅ ខ្ញុំក៏បានមកទិញដីនីក្រោយចឹងទៅណាស់។

កៈ បាទម៉ាក់យាយ គេចែកដីអោយនៅនឹង?

ខៈ គេមិនចែកទេ យើងទិញគេតា។

កៈ ចុះម៉ាក់យាយមានបងប្អូន រឺមួយក៏កូនចៅណាដែរមាន ទៅរស់នៅក្រៅពីស្រុកខ្មែរទេម៉ាក់យាយ?

ខ៖ អត់មានផងនឹង។

ក៖ អត់មានទេណាម៉ាក់យាយ?

ខ៖ អត់ទេ។

ក៖ ចុះម៉ាក់យាយធ្លាប់បានរៀនទេ?

ខ៖ រៀនដែរនឹងហាស។

ក៖ រៀនបានថ្នាក់ទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖ ខ្ញុំពីដើមរៀនបានថ្នាក់ទី7ដែរនឹង។

ក៖ អូ្ន!រៀនបានថ្នាក់ទី7ហោសម៉ាក់យាយ?

ខ៖ ចា៎!តែឥឡូវនឹងភ្លេចអស់ហើយ។

ក៖ អូ្ន!កាលពីម៉ាក់យាយរៀននឹងម៉ាក់យាយរៀននៅណាដែរ?

ខ៖ រៀននៅកំពង់រូល។

ក៖ រៀននៅកំពង់រូល ចុះឈ្មោះសាលាម៉ាក់យាយមានចងចាំទេ?

ខ៖ អត់ចាំផងនឹង។

ក៖ អត់ចាំទេម៉ាក់យាយ?

ខ៖ ដូចជាសាលាកំពង់រូលនឹងតែម្ដងនឹងហាស។

ក៖ ចុះម៉ាក់យាយមានមិត្តភក្ដិដែរធំធាត់មកជាមួយគ្នាទេ ដែរស្និទ្ធស្នាលហាស?

ខ៖ អើយចាស់ៗអស់ហើយនឹងគេបែកអស់ហើយនឹង។

ក៖ ប៉ុន្តែម៉ាក់យាយមាននៅចាំឈ្មោះពួកគាត់ដែរទេម៉ាក់យាយ?

ខ៖ អត់ចាំផង បែកគ្នាអស់ហើយនឹងហាស មិនដឹងថាទៅណាទៅណីអស់ហើយនឹងហាស វានៅស្គាល់ឈ្មោះតែមិនដឹងថាទៅណាទីណីនឹង។

ក៖ ប៉ុន្តែអាចប្រាប់ឈ្មោះម្នាក់ពីរដើម្បីអាចស្គាល់ចឹងហាស?

ខ៖ មីមួយនោះឈ្មោះមី សួនពួកម៉ាកដែរ។

ក៖ គាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖ ឈ្មោះមី សួន។

កៈ ឈ្មោះ សួន?

ខៈ នៅចាំតែឈ្មោះមួយនឹងមិនដឹងថាទៅណាអស់ទៀតទេនេះ?

កៈ ចុះម៉ាក់យាយមានចងចាំអនុស្សាវរីយ៍អី
ជាមួយមិត្តភក្តិរបស់ម៉ាក់យាយកាលពីម៉ាក់យាយនៅរៀនជាមួយគ្នាទេ?

ខៈ អត់មានផងនឹងបែកគ្នាអស់ហើយនឹងហាស។

កៈ អូ៎!បែកគ្នាអស់ហើយហោសម៉ាក់យាយ?
ខៈ នឹងហើយគេចាស់ៗអស់ហើយនឹង។

កៈ ពីមុននឹងក៏មិនធ្លាបដែរ ចង់និយាយថាកាលពីមុននឹងធ្លាប់
លេងចុយអីជាមួយមិត្តភក្តិម៉ាក់យាយហាសមានទេ?

ខៈ អត់មានដែរលេងអីទេរវល់ណាស់ គ្មានបានដែរលេងទេក្មេងពីដើមហោស។

កៈ អូ៎!បាទម៉ាក់យាយ?

ខៈ ការងារជួនកាលមកពីរៀនចឹងទៅ មើលនេះមើលនោះអី រវល់ការងារច្រើនដែរ។

កៈ អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ មិនសូវបានដើរលេងទេ។

កៈ ចុះម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេម៉ាក់យាយ?

ខៈ អត់មានចេះទេ ចេះតែភាសាខ្មែរនឹងហាស។

កៈ ចុះវៀតណាម ថៃអីម៉ាក់យាយអត់ចេះដែរ?

ខៈ អត់ទេ ទាល់តែកូនស្រីរបស់ខ្ញុំបានចេះ។

កៈ ចុះម៉ាក់យាយធ្លាប់ទៅធ្វើការងារនៅវាលស្រែទេ?

ខៈ ថីមិនទៅ។

កៈ ចុះពេលដែរម៉ាក់យាយទៅស្រែម៉ាក់យាយធ្វើអីគេខ្លះនៅណុងដែរ?

ខៈ ធ្វើអីធ្វើតែស្រែនឹង ច្រូតស្រូវនឹងហាស ស្ទូង ច្រូតតែប៉ុណ្ណឹង។

កៈ បាទម៉ាក់យាយ ចុះម៉ាក់យាយធ្លាប់ធ្វើអាជីវកម្មនៅក្នុងក្រុមគ្រួសារដែរទេម៉ាក់យាយ?

ខៈ ថីមិនធ្វើ។

កៈ ម៉ាក់យាយធ្វើអីគេដែរ?

ខៈ រាល់ថ្ងៃហោស?

កៈ បាទម៉ាក់យាយ?

ខៈ រាល់ថ្ងៃនឹងដាំបាយ លក់បានបន្តិចបន្តួចអីនឹងហាស។

កៈ អូ៎!ម៉ាក់យាយលក់បាយដែរហោស?

ខៈ នឹងលក់ប្រចាំហូបរាល់ថ្ងៃនឹងទៅ។

កៈ ចុះម៉ាក់យាយធ្លាប់មានចិញ្ចឹមសត្វទេ ចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របីអីហាសម៉ាក់យាយ?

ខៈ អត់មានចិញ្ចឹមទេ ពីមុនចិញ្ចឹម តែឥឡូវនឹងអត់មានចិញ្ចឹមទេ កាលនៅលើថ្នល់នឹងចិញ្ចឹមដែរតា។

កៈ ចុះម៉ាក់យាយចិញ្ចឹមលក្ខណៈថាជាលក្ខណៈក្រុមគ្រួសារ រឺមួយក៏ចិញ្ចឹមជាលក្ខណៈកសិដ្ឋានដែរម៉ាក់យាយ?

ខៈ ចិញ្ចឹមលក្ខណៈជាគ្រួសារតា។

កៈ ចុះម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់ម៉ាក់យាយ តាំងពីក្មេងរហូតមកដល់ពេលនេះដែរហាស?

ខៈ ការងារអីក៏ធ្វើដែរសព្វគ្រប់នឹងហាស។

កៈ ធ្វើច្រើនហោសម៉ាក់យាយ?

ខៈ នឹងហើយការងារអីក៏ធ្វើដែរ អីក៏រកលក់ដែរនឹងហាស សព្វគ្រប់ការងារ។

កៈ តាំងពីម៉ាក់យាយនៅក្មេងនឹងហោសម៉ាក់យាយ?

ខៈ នឹងហើយតាំងពីក្មេងរហូតដល់មានប្តីក៏ការងារមិនចេះចប់ដែរនឹងហាស។

កៈ អូ៎!ធ្វើរហូតហោសម៉ាក់យាយ?

ខៈ នឹងហើយធ្វើរហូតនឹងហើយ ចុះបើមិនធ្វើមានអីហូបទៅ។

កៈ អូ៎!នឹងហោសម៉ាក់យាយ?

ខៈ ធ្វើរហូតនឹង ធ្វើទាំងថ្ងៃទាំងយប់នឹងហាស។

កៈ ម៉ាក់យាយធ្វើការងារច្រើន?

ខៈ នឹងហើយធ្វើគ្មានពេលដេកទេ ចេះតែធ្វើទៅចុះបើយើងអត់ធ្វើម៉េច។

កៈ បាទត្រូវហើយម៉ាក់យាយ។

ខៈ ចុះបើយើងមិនធ្វើមានអីហូប។

កៈ ចុះម៉ាក់យាយគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស
តើជីវិតរបស់ម៉ាក់យាយមានការផ្លាស់ប្តូរអីគេខ្លះដែរម៉ាក់យាយ?

ខៈ មិនដែរផ្លាស់ប្តូរអីទេ។

កៈ ពីក្មេងយ៉ាងម៉េច ហើយឥឡូវនឹងយ៉ាងម៉េចចឹងហាស?

ខៈ ពីក្មេងមានកំលាំង ហើយឥឡូវនឹងមានកំលាំងអីទៀត។

កៈ បាទត្រូវហើយម៉ាក់យាយ។

ខៈ រកមិនបានស្អីដូចពីក្មេងទេនឹងហាស។

កៈ សូម្បីតែសុខភាពនឹងម៉េចដែរ?

ខៈ សុខភាពនឹងក៏ខ្សត់ខ្សោយដែរនឹងហាស
ហើយវាក៏ចាស់ហើយក៏រកអីមិនបានដែរកូនអើយ។

កៈ ចុះជីវភាពវិញម៉ាក់យាយ?

ខៈ ជីវភាពនឹងក៏អត់ដែរ មិនត្រឹតែអត់ទេមានការជំពាក់គេទៀតនឹងហាស។

កៈ អ៊ូ!បាទម៉ាក់យាយ។

ខៈ រកលុយធ្វើផ្ទះ។

កៈ ចុះម៉ាក់យាយចូលចិត្តម្ហូបអីគេដែរម៉ាក់យាយ?

ខៈ ខ្ញុំចូលចិត្តតែត្រីទេ។

កៈ ម៉ាក់យាយចូលចិត្តត្រីណាម៉ាក់យាយ?

ខៈ ចូលចិត្តត្រី សំរាប់មាន់អីយូរៗម្តងអីចឹងហាស។

កៈ អ៊ូ!ម៉ាក់យាយចូលចិត្តត្រីច្រើន?

ខៈ នឹងហើយបើត្រីនឹងចិតថេរនឹង។

កៈ
ចុះម៉ាក់យាយចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេតាំងពីក្មេងរហូតមកដល់ពេលនេះហាស ដូចជាបោះអង្គុញ ចោលឈូង ទាញព្រាត លាក់កន្សែងអីចឹងហាស?

ខៈ ខ្ញុំមិនសូវបានលេងអីនឹងគេផងនឹងហាស។

កៈ អូ៎!ម៉ាក់យាយគ្រាន់តែទៅមើលគេហោស?

ខៈ នឹងហើយខ្ញុំមិនសូវបានចេះលេងអីនឹងគេទេ។

កៈ ចុះម៉ាក់យាយកាលពីនៅក្មេងម៉ាក់យាយចូលចិត្តច្រៀងទេ?

ខៈ ចូលចិត្តដែរប៉ុន្តែមិនសូវបានច្រៀងទេ។

កៈ អូ៎!ម៉ាក់យាយចូលចិត្តដែរហោស?

ខៈ ចូលចិត្តដែរប៉ុន្តែមិនសូវបានច្រៀងទេនឹងហាស ហើយអត់ចេះរាំ។

កៈ ប៉ុន្តែម៉ាក់យាយចូលចិត្តស្តាប់?

ខៈ នឹងហើយចូលចិត្តស្តាប់
ហើយនឹងមើលទូរទស្សន៍រាល់ថ្ងៃនឹងចេះតែមើលហើយនឹងហាស ខ្ញុំចូលចិត្តមើលចំរៀង។

កៈ ចុះលក្ខណៈថាជាលក្ខណៈបទសម័យ រឺបទបុរាណដែរម៉ាក់យាយ?

ខៈ ជាធម្មតាគ្រប់តែចំរៀងនឹងធម្មតាៗទាំងអស់នឹងហាស។

កៈ បាទម៉ាក់យាយ ចុះមាននរនាគេម្នាក់នៅក្នុងផ្ទះ
រឺនៅក្នុងក្រុមគ្រួសាររបស់ម៉ាក់យាយចេះលេងឧបករណ៍ភ្លេងទេ?

ខៈ ចេះលេងភ្លេងហោស?

កៈ បាទលក្ខណៈភ្លេងខ្មែរ ភ្លេងពិណពាត ភ្លេងសៀមអីចឹងហាស។

ខៈ អត់ទេ។

កៈ បងប្អូនជីដូនមួយក៏អត់មានអ្នកចេះដែរ?

ខៈ អត់មានអ្នកចេះលេងទេ ចង់រកអ្នកលេងភ្លេងហោស?

កៈ អត់ទេគ្រាន់តែសួរចឹងហាស?

ខៈ អូ៎!អត់មានទេ។

កៈ ចុះផ្ទះរបស់ម៉ាក់យាយមានលក្ខណះបែបណាដែរ តាំងពីក្មេងរហូតមកដល់ឥឡូវហាស ពីក្មេងផ្ទះយ៉ាងម៉េចហើយ ឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?
ខៈ ផ្ទះគ្មានយ៉ាងម៉េចទេនេះ កាលពីក្មេងផ្ទះថ្មផង ដល់ពេលដែរមកនៅក្រោមផ្ទះឈើវិញ គ្មានអីទេនឹងហាស។

កៈ ចុះផ្ទះរបស់ម៉ាក់យាយនឹងនរណាគេជាអ្នកសាងសងដែរម៉ាក់យាយ?

ខៈ ខ្ញុំពីរនាក់តារបស់ខ្ញុំជាអ្នកសាងសងនឹងហាស។

កៈ អូ៎!ជួលគេធ្វើហោស?

ខៈ នឹងហើយជួលគេធ្វើ ហើយលុយកាក់អីនឹងធ្វើខ្លួនឯង។

កៈ
ម៉ាក់យាយមានដឹងថាផ្ទហរបស់ម៉ាក់យាយនឹងគេមានប្រើឧបករណ៍អីគេខ្លះដែរសំរាប់សាងសងដែរចឹងហាសម៉ាក់យាយ?

ខៈ ឧបករណ៍អីមានតែឈើ នឹងថ្មនឹងហាស។

កៈ អូ៎!បាទម៉ាក់យាយ?

ខៈ នឹងហើយ។

កៈ ចុះម៉ាក់យាយគិតថាមានជំនាញអីដែរម៉ាក់យាយចេះស្ទាត់ចំនាញដែរម៉ាក់យាយ?

ខៈ ថាម៉េចដែរ?

កៈ ជំនាញអីដែរម៉ាក់យាយស្ទាត់ជំនាញធ្វើហាស?
ខៈ ជំនាញធ្វើការងាររាល់ថ្ងៃនឹងហោស?

កៈ បាទនឹងហើយម៉ាក់យាយ។

ខៈ គ្មានអីដែរចេះស្ទាត់ទេនឹងហាស ជំនាញធ្វើម្ហូប ធ្វើបាយអីនឹងអោយតែមានទៅចេះតែធ្វើហើយនឹងហាស។

កៈ ចឹងម៉ាក់យាយស្ទាត់ជំនាញជាងគេគឺធ្វើបាយធ្វើម្ហូប?

ខៈ នឹងហើយធ្វើបាយ ធ្វើម្ហូប។

កៈ ចុះម៉ាក់យាយមានបង្រៀនអោយចេះធ្វើអីទេ ដូចជាវេញវល្លិ៍ កូរស្ករ ធ្វើកន្ទេលអីទេ?

ខ៖ អត់ទេ។

ក៖ អត់ទេហោសម៉ាក់យាយ?

ខ៖ ពីព្រោះនៅស្រុករបស់ខ្ញុំអត់មានត្នោត។

ក៖ អូ៎!ធ្វើកន្ទេល ធ្វើល្អីក៏អត់ដែរ?

ខ៖ អត់ទេនឹងហាស។

ក៖
ចុះម៉ាក់យាយអាចប្រាប់បានទេថាពេលណាដែរម៉ាក់យាយគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយហាស?

ខ៖ ពិបាកជាងគេរាល់ថ្ងៃនឹងមានតែជំពាក់បំណុលគេនឹងហាស
នឹងពិបាកណាស់គ្មានអីសងគេទេកូនអើយ។

ក៖ អូ៎!បាទម៉ាក់យាយ?

ខ៖ ហាត់ណាស់។

ក៖ ចុះម៉ាក់យាយគិតថាពីក្មេងម៉ាក់យាយមានការលំបាកអីគេដែរម៉ាក់យាយ?

ខ៖ កាលពីក្មេងគ្មានលំបាកអីគេទេនេះ។

ក៖ ចឹងម៉ាក់យាយអត់មានការលំបាកទេ?

ខ៖ នឹងហើយទើបមកចាស់ខ្លួនតា ដែរលំបាកជំពាក់គេ
ជំពាក់អង្គការយកលុយមកធ្វើផ្ទះនឹងហាស ចាក់ដីចាក់អីនឹង ហើយរកសងគេមិនបានទេ។

ក៖ អូពិបាកដែរហោសម៉ាក់យាយ?

ខ៖ នឹងហើយរាល់ថ្ងៃទឹកភ្នែក ទឹកសំបោហើយ។

ក៖ បាទម៉ាក់យាយ ចុះពេលដែរជំនាន់ពលពត
ម៉ាក់យាយគិតថាមានការលំបាកអីគេខ្លះដែរម៉ាក់?

ខ៖ ជំនាន់ពលពតនឹងវាពិបាករឿងហូបចុកនឹងហាស។

ក៖ អូ៎!ពិបាកហូបចុកហោសម៉ាក់យាយ?

ខ៖ នឹងហើយ ហូបមិនគ្រប់គ្រាន់អីប្រើអោយធ្វើការងារ ខ្លាំងៗធ្ងន់
ដូចខ្ញុំកាលពីជំនាន់អាពត វាយើងនៅវ័យកណ្ដាលហើយណាស់។

កៈ បាទម៉ាក់យាយមានអីទៀត?

ខៈ គេថាកំលាំងទីមួយគេអោយទៅសម័រភូមិខាងមុខ។

កៈ បាទម៉ាក់យាយ?

ខៈ សំរាប់កំលាំងទៅ2នឹងគេអោយដើរនៅខាងក្រោយ គេអោយកិនស្រូវ កិនអង្ករអីចឹងទៅ អង្ករ20ប៉ាវអីចឹងហាស។

កៈ បាទត្រូវហើម៉ាក់យាយ?

ខៈ នឹងហើយគេបំបែកគ្នាចឹងហាស។

កៈ មានអីទៀតទេ?

ខៈ នឹងហើយគេធ្វើបាន20ប៉ាវអីចឹងហាស ដឹកជញ្ជូនទៅសមរភូមិ ទាល់តែម៉ោង10យប់អីបានបានមកផ្ទះ ការងារខ្លះទៅកិន ខ្លះទៅដៃរនឹង។

កៈ គេជំលាសម៉ាក់យាយទៅនាដែរទៅ។

ខៈ គេជំលាសទៅគៀនស្វាយ។

កៈ អូ៎!បាទម៉ាក់យាយ។

ខៈ ពេលណុងខ្ញុំអត់ទៅភ្នំពេញផងនឹងហាស។

កៈ ចុះម៉ាក់យាយនៅឆ្ងាយពីក្រុមគ្រួសារដែរពេលណុង?

ខៈ នៅឆ្ងាយពីក្រុមគ្រួសារមានគ្រួសារណាទៀតបើបែកគ្នាហើយនឹង ម្តាយឪពុករបស់ខ្ញុំស្លាប់នៅពេលជំនាន់លុណនុលទាំងអស់នឹងហាស។

កៈ អូ៎!ចឹងមានន័យថាម៉ាក់យាយនៅម្នាក់ឯងទេ កាលពីនៅពលពត?

ខៈ នឹងហើយណោម្នាក់ឯងកាលពីនៅអាពត។

កៈ ប៉ុន្តែគេអោយម៉ាក់យាយទៅជាមួយមិត្តភក្តិទៅណុង?

ខៈ អត់ទេមានមិត្តភក្តិណាទេ គេចែកជាក្រុមៗតែម្តងនឹងគេអោយ រាប់អានគ្នាដូចជាបងប្អូនចឹងហាស អ្នកដទៃអីក៏ដោយ។

កៈ អូ៎!គេគិតចឹងហោស?

ខៈ នឹងហើយ។

កៈ  បាទ ចុះម៉ាក់យាយឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរម៉ាក់យាយ?

ខៈ  ឆ្លងកាត់គ្រប់សព្វអស់ហើយកូនអើយ។

កៈ  អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ  វេទនាអីក៏ឆ្លងកាត់ដែរនឹង។

កៈ  អូ៎!បាទម៉ាក់យាយ?

ខៈ  ឆ្លងកាត់វេទនា ឆ្លងកាត់អត់បាយ ស្អីក៏ឆ្លងកាត់ដែរ។

កៈ
ចុះម៉ាក់យាយគិតថាពេលណាដែរគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយដែរ?

ខៈ  អត់ដឹងទេ បើអត់ដែរបានសប្បាយផងនឹង។

កៈ  ចុះពេលដែរម៉ាក់យាយការហាស ម៉ាក់យាយគិតថាម៉ាក់យាយសប្បាយទេ រឺមួយក៏កូនៗការអីចឹងហាស?

ខៈ  កូនៗការក៏មិនសប្បាយដែរ ចេះតែធ្វើអោយតែគ្រប់ៗអោយវានឹងហាស យើងវាអត់លុយចឹងសប្បាយទៅម៉េចនឹងរួចដែរ។

កៈ  អូ៎!បាទម៉ាក់យាយ?

ខៈ  អត់លុយ អត់មានកាក់អីសប្បាយ យើងសប្បាយទៅមិនរួចទេ ការអោយតែគ្រប់ៗនឹងរួចអាងនឹងសងគេនឹងហាស។

កៈ  បាទម៉ាក់យាយត្រូវ។

ខៈ  ពេលដែរសងរួចទៅក៏សងទៅ ពេលណាដែរសងមិនរួចក៏មិនរួចដែរទៅ យើងដេកមិនលក់ទេ អោយសព្វគ្រប់នឹងហាស។

កៈ  ចុះម៉ាក់យាយធ្លាប់គិតថាពេលដែរនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយនឹង តើម៉ាក់យាយធ្លាប់មានក្តីស្រម៉ៃទេ ដូចថាចង់ធ្វើអីគេចឹងហាស?

ខៈ  វាតែងតែមានក្តីស្រម៉ៃហើយ ចង់មានចង់បាន តែវាមិនមាន វាមិនបានចឹងហាស។

កៈ  អូ៎!ចឹងហោសម៉ាក់?

ខ៖ ចេះតែនឹកឃើញហើយ ពេលដែរនឹកឃើញនឹងវាមិនមានមិនបាន បើចេះតែជួបទុករហូតនឹងហាសកូន?

ក៖ ចុះបើចង់អោយម៉ាក់យាយផ្ដែផ្ដាំអីទៅពួកគាត់ហាស តើម៉ាក់យាយចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖ នឹងហើយបើផ្ដែផ្ដាំទៅ បើវាតាមក៏តាម តែបើវាមិនតាមក៏មិនតាមទៅចឹងហាស

ក៖ ប៉ុន្តែម៉ាក់យាយចង់និយាយផ្ដែផ្ដាំអី ដើម្បីអោយពួកគាត់ដែរហាស អោយពួកគាត់ធ្វើតាមម៉ាក់យាយចឹងហាស?

ខ៖ ហឺ!មិនដឹងនិយាយអីទេ។

ក៖ ចង់និយាយថាម៉ាក់យាយាចង់និយាយអីទៅកូនចៅជំនាន់ក្រោយៗដើម្បីអោយពួកកាត់នឹងធ្វើតាមម៉ាក់យាយចឹងហាស?

ខ៖ ផ្ដែផ្ដាំវាដែរ បើវាតាមក៏តាម តែបើវាមិនតាមក៏មិនដឹងធ្វើម៉េចដែរទេ។

ក៖ ម៉ាក់យាយអាចផ្ដែផ្ដាំបានទេ ថាម៉ាក់យាយចង់ផ្ដែផ្ដាំអីគេខ្លះដែរចឹងហាស?

ខ៖ ចង់ផ្ដែផ្ដាំថាកុំអោយវាទៅនេះវាទៅ កុំអោយវាទៅនោះក៏វាទៅចឹងហាស ចេះតែប្រាប់ៗវាទៅថាអោយវារកធ្វើចង់មានចង់បានអីចឹងហាស។

ក៖ អូ៎!បាទម៉ាក់យាយមានអីទៀតទេ?

ខ៖ បើវាតាមក៏តាមទៅ បើវាមិនតាមក៏តាមចិត្តទៅ។

ក៖ អូ៎!បាទម៉ាក់យាយ?

ខ៖ នឹងហើយមានតែចឹង ។

ក៖ ចឹងចាចុងក្រោយចៅអរគុណម៉ាក់យាយដែរបានអោយចៅពិភាក្សានឹង ដូចជាបានផ្ដល់ប្រវត្តិរបស់ម៉ាក់យាយចឹងហាស ហើយចៅនឹងរក្សាពីប្រវត្តិមួយទៅក្នុងវេបសាយរបស់សាលា ដើម្បីអើយសាលាទុកអោយកូនចៅជំនាន់ក្រោយចឹងហាស នឹងស្គាល់បីប្រវត្តិដូចតាដែរម៉ាក់យាយបានរៀបរាប់មិញចឹងហាសម៉ាក់យាយ បាទអរគុណច្រើនម៉ាក់យាយ៕៕៕